King County

Bitfocus

401 Fifth Avenue
Seattle, WA 98104

Bitfocus, Inc.

5940 S Rainbow Blvd Ste 400 #60866
Las Vegas, Nevada 89118-2507

# ប្រព័ន្ធគ្រប់គ្រងព័ត៌មានអ្នកគ្មានលំនៅស្ថាន
# សន្លឹកព័ត៌មានអតិថិជន

**តើ HMIS គឺជាអ្វី**?
HMIS មកពីពាក្យប្រព័ន្ធគ្រប់គ្រងព័ត៌មានអ្នកគ្មានលំនៅស្ថាន និងជាលក្ខខណ្ឌមួយសម្រាប់កម្មវិធីនិងភ្នាក់ងារទាំងអស់ក្នុងការផ្តល់សេវាដល់គ្រួសារចំណូលតិចនិងគ្មានលំនៅស្ថានដែលត្រូវគាំទ្រដោយមូលនិធិរដ្ឋសហព័ន្ធ។ HMIS គឺជាប្រព័ន្ធទិន្នន័យដែលរក្សាទុកព័ត៌មានអំពីសេវាកម្មសម្រាប់គ្មានលំនៅស្ថាន

**តើប្រព័ន្ធ HMIS មានគោលបំណងដូចម្តេច?**
គោលបំណងនៃ HMIS គឺដើម្បីពង្រឹងសេវាកម្មដែលគាំទ្រដល់ការទទួលលំនៅស្ថាន និងដើម្បីប្រើប្រាស់សេវាទាំងនោះបានប្រសើរ។

**ហេតុអ្វីបានជាប្រភេទនៃព័ត៌មាននេះត្រូវបានប្រមូល?**
ទិន្នន័យអតិថិជននឹងត្រូវបានប្រើដោយមន្ត្រីនៅសហព័ន្ធ រដ្ឋ និងមូលដ្ឋានដើម្បីដោះស្រាយតម្រូវការដល់ជនគ្មានលំនៅស្ថាន។ ការប្រមូលព័ត៌មានមូលដ្ឋានខ្លះ (ពូជសាសន៍ ថ្ងៃខែឆ្នាំកំណើត ទំហំគ្រួសារ។ល។) អំពីអ្នកនិងសមាជិកគ្រួសាររបស់អ្នកគឺជាលក្ខខណ្ឌនៃការផ្តល់មូលនិធិមូលដ្ឋាននិងសហព័ន្ធដែលគាំទ្រគម្រោងនេះ។

**តើប្រព័ន្ធ HMIS អាចផ្តល់អត្ថប្រយោជន៍យ៉ាងដូចម្តេចដល់ខ្ញុំ, អតិថិជន?**
ដោយការប្រមូលព័ត៌មាននេះម្តងពីអ្នក មានន័យថាអ្នកអាចត្រូវបានបម្រើដោយភ្នាក់ងារផ្សេងដោយគ្មានរាយការណ៍ពិស្តារទាំងអស់ (ថ្ងៃខែឆ្នាំកំណើត លេខសន្តិសុខសង្គម អាសយដ្ឋានចុងក្រោយ។ល។) ម្តងទៀតនោះទេ។ ប្រសិនបើមានហេតុផលថាការផ្តល់ឈ្មោះរបស់អ្នក ឬឈ្មោះសមាជិកណាមួយនៃគ្រួសាររបស់អ្នកអាចធ្វើឱ្យអ្នក (ឬសមាជិកគ្រួសាររបស់អ្នក) មានហានិភ័យ នោះអ្នកអាចស្នើមិនឱ្យចែករំលែកព័ត៌មានរបស់អ្នកទៅភ្នាក់ងារផ្សេងទៀត។ អ្នកមានសិទ្ធិដកការចែករំលែកព័ត៌មានរបស់អ្នកមកវិញនៅគ្រប់ពេលដោយគ្រាន់តែបំពេញទម្រង់ "ការដកហូតការយល់ព្រមរបស់អតិថិជននិងការបញ្ចេញព័ត៌មាន"។ ទម្រង់បែបបទនេះអាចរកបានទីភ្នាក់ងារចូលរួម HMIS ណាមួយ ឬនៅលើវិបសាយរបស់ឃីងខោនធី (King County): kingcounty.hmis.cc។

លើសពីនេះ តាមរយៈការប្រើប្រាស់ព័ត៌មានដែលអ្នកផ្តល់ឲ្យ HMIS អ្នក និងបុគ្គលិកកាន់ករណីរបស់អ្នកអាចធ្វើការជាមួយគ្នា ឬសហការគ្នាដើម្បីកំណត់បញ្ហាសេវាកំណត់លំនៅដ្ឋាន និងសេវាកម្មនានាដែលអ្នកចាំបាច់ត្រូវការនិងធ្វើការទទួលបានសេវាទាំងនេះ។

**តើនរណាខ្លះអាចចូលមើលព័ត៌មានរបស់ខ្ញុំ?**
ព័ត៌មាន HMIS របស់អ្នកអាចមានការចែករំលែកដោយបណ្តាទីភ្នាក់ងារដៃគូ ដើម្បីសម្របសម្រួលដល់ការបញ្ជូនបន្ត និងការស្នើសុំសេវាលំនៅដ្ឋាន និងសេវាកម្មនានាដែលមានប្រភេទដូចជា ការប្រឹក្សា, ចំណីអាហារ, ជំនួយលើសេវាសាធារណៈសំខាន់ៗ, និងសេវាផ្សេងៗទៀត។ របាយការណ៍អ្នកអភិវឌ្ឍនិងបុគ្គលិក HMIS ក៏អាចមើលទិន្នន័យរបស់អ្នកផងដែរ។ វាមានគោលការណ៍ច្បាប់តឹងរឹងសម្រាប់អ្នកដែលអាចចូលមើលព័ត៌មានរបស់អ្នក ហើយវាត្រូវបានការពារដោយការដាក់កូដអេឡិកត្រូនិក។

**តើអ្នកក្នុងនាមជាអតិថិជនមានសិទ្ធិអ្វីខ្លះ:?**
អ្នកអាចត្រូវបានតម្រូវឱ្យឆ្លើយសំណួរខ្លះសម្រាប់ចូលក្នុងកម្មវិធី ប៉ុន្តែអ្នកមានសិទ្ធិជ្រើសយកមិនឆ្លើយនឹងសំណួរ។ អ្នកមានសិទ្ធិពិនិត្យមើលកំណត់ត្រារបស់អ្នកនិងកែតម្រូវព័ត៌មានមិនត្រឹមត្រូវ។ អ្នកក៏មានសិទ្ធិថតចម្លងកំណត់ត្រាផងដែរ។ យើងនឹងមិនផ្តល់ព័ត៌មានណាមួយអំពី (សុខភាព តម្រូវការវេជ្ជសាស្ត្រ សុខភាពផ្លូវចិត្ត អំពើហិង្សាក្នុងគ្រួសារ។ល។) របស់អ្នកទៅអ្នកណាម្នាក់ក្រៅពីក្រុមហ៊ុនឡើយ លើកលែងតែអ្នកបានផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរ ឬតម្រូវដោយច្បាប់តាមរយៈដីកាឬដីកាតុលាការ។ ការកំណត់ប្រភេទព័ត៌មានដោយខ្លួនឯងដែលមានដូចជាឈ្មោះ និងថ្ងៃខែឆ្នាំកំណើត នឹងមានការលុបចេញក្នុងរយៈពេលប្រាំពីរឆ្នាំក្រោយសកម្មភាព HMIS ដែលបានកត់ត្រាទុកចុងក្រោយរបស់អ្នក។ អ្នកនឹងទទួលសេវាទោះបីអ្នកបានផ្តល់ឬមិនផ្តល់ព័ត៌មានកំណត់អត្តសញ្ញាណរបស់អ្នកទៅក្នុង HMIS ក្តី។

ទម្រង់បែបបទនេះអាចមិនត្រូវបានកែប្រែឡើយលើកលែងតែមានការអនុម័តពីគណៈកម្មការ HMIS
សូមបញ្ជូនសំណើសុំការផ្លាស់ប្តូរទាំងអស់ទៅកាន់: kcsupport@bitfocus.com